# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាបន្ទរឱ្យមានការដោះលែងពលរដ្ឋពីររូបក្នុងសំណុំរឿងព្រំដែន

*ដោយ : ឫទ្ធិ ពល*
*ព័ត៌មានថ្ងៃទី ២៩-១២-២០០៩*
*ទស្សនាវដ្ដី សារព័ត៌មានសេរី (Free Press Magazine). www.fpmonline.net*

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា ដែលមានមូលដ្ឋាននៅប្រទេសន័រវេ៉ បានបន្ទរការទាមទារឱ្យរដ្ឋាភិបាលដោះលែងពលរដ្ឋខ្មែរពីររូប ដែលតុលាការខេត្តស្វាយរៀង សម្រេចឃុំខ្លួនឱ្យមានសេរីភាពឡើងវិញ ។

លោក ម៉ែន ណាត ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា បានបញ្ជាក់នៅក្នុងសេចក្ដីថ្លែងការណ៍មួយរបស់ខ្លួនកាលពីថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០០៩ ពីទីក្រុងគ្រីស្ទានសាន់ ប្រទេសន័រវេ៉ថា "ត្រូវបញ្ឈប់ការប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីចាប់ខ្លួនប្រជាពលរដ្ឋរងគ្រោះ និងត្រូវដោះលែងជនរងគ្រោះទាំងពីររូប គឺលោក ព្រំ ជា និងអ្នកស្រី មាស ស្រី ឱ្យមានសេរីភាពដោយឥតលក្ខខណ្ឌ" ។

លោក ព្រំ ជា និងអ្នកស្រី មាស ស្រី ក្នុងចំណោមមនុស្ស៩នាក់ដែលមានដីកាកោះហៅសាកសួរ ត្រូវបានតុលាការខេត្តស្វាយរៀង សម្រេចឃុំខ្លួនកាលពីថ្ងៃពុធ ទី២៣ ខែធ្នូ និង៣នាក់ទៀតដែលត្រូវចូលបន្ទាប់ បានរត់គេចខ្លួនដោយសេចក្ដីភិតភ័យ ។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា បានធ្វើការរិះគន់ចំពោះទិដ្ឋភាពនេះ ដោយលើកឡើងនៅក្នុងសេចក្ដីថ្លែងការណ៍របស់ខ្លួនថា "រដ្ឋាភិបាលកម្ពុជាកំពុងបម្រើឱ្យនយោបាយប្រទេសវៀតណាម ដោយដាក់ទណ្ឌកម្មមកលើប្រជាពលរដ្ឋខ្លួនឯងដើម្បី ផ្គាប់ចិត្តរដ្ឋាភិបាលក្រុងហាណូយ" ។ ហើយក៏បានធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការដល់រដ្ឋាភិបាលកម្ពុជា ក្នុងការបោះបង្គោលព្រំដែនកម្ពុជា-វៀតណាម ដែលបានធ្វើឱ្យបាត់បង់ដីស្រែចំការរបស់ប្រជាពលរដ្ឋនៅតាមបណ្ដោយព្រំដែន (ព្រំដែនគោក) ចន្លោះពី៤ពាន់ ទៅ៦ពាន់គីឡូម៉ែត្រក្រឡា ។

ជាមួយគ្នា ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា ក៏បានសម្ដែងការខកចិត្តយ៉ាងធ្ងន់ធ្ងរផងដែរ ចំពោះការឆ្លើយបំភ្លឺដល់រដ្ឋសភារបស់លោក វ៉ា គឹមហុង ប្រធានគណកម្មាធិការព្រំដែនរបស់រដ្ឋាភិបាលខ្មែរ តបសំណួររបស់លោក សុន ឆ័យ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី ។ ដែលចម្លើយគឺជាការព្យាយាមពង្វាងប្រាសចាកពីសំណួរ ។

ទង្វើបែបនេះ ត្រូវបានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា ចាត់ទុកថា រដ្ឋាភិបាលកម្ពុជាមិនត្រឹមតែគ្មានឆន្ទៈការពារបូរណភាពទឹកដីប៉ុណ្ណោះទេ គឺថែមទាំងបណ្ដោយឱ្យប្រទេសជិតខាងឈ្លានពានទឹកដីខ្មែរ ព្រមទាំងព្យាយាមការពារបរទេស ក្នុងការលេបទឹកដីខ្មែរទៀតផង ។/

---

## CWCI CALLS FOR THE RELEASE OF 2 VILLAGERS IN THE BORDER CASE

29 Dec 2009
By **Rithipol**
***Free Press Magazine***
*Translated from Khmer by Socheata*

The Norway-based Cambodia Watchdog Council International (CWCI) demanded that the Cambodian government release the two Khmer villagers whom the Svay Rieng tribunal decided to imprison.

Men Nath, the Chairman of the CWCI, indicated in a statement released on 27 December 2009 from

Kristiansand, Norway, that “the court should stop being used to arrest the victimized villagers and the latter, Mr. Prum Chea and Mrs. Meas Srey, should be unconditionally released.”

Mr. Prum Chea and Mrs. Meas Srey were among 5 villagers who were summoned by the Svay Rieng court for questioning, and they were placed under arrest on Wednesday 23 December. The other 3 villagers fled in fear.

CWCI criticized this situation. It indicated in its statement that “the Cambodian government is serving Vietnam’s policy by inflicting sentences on its own people to please the Hanoi’s regime.” CWCI also condemned the Cambodian government in the planting of border posts that led to the loss of 4,000 to 6,000 square-kilometers of rice fields belonging to Cambodian villagers living along the border.

CWCI also expressed its extreme disappointment in the answers provided by Var Kim Hong, the chairman of the government border committee, to the National Assembly based on the questions raised by SRP MP Son Chhay. During the clarification session, all that Var Kim Hong did was to dodge the questions asked.

With all that can be seen above, CWCI considered that not only the Cambodian government does not have the will to defend Cambodia’s national integrity, but it also allows neighboring countries to encroach on Cambodian territories, and the government made all attempts to defend these countries in their swallowing of Cambodian territories.